

# ដំណើរកម្សាន្តដ៏អស្ចារ្យ

Kim Ann Arun

Seat Sopheap

Let's Read

The Asia Foundation



នៅមាត់ព្រែកមួយ ទីតូអផ្សុកអង្គុយក្រៀមក្រំ។ រីកា ជាប្អូនស្រី ជីដូនមួយ បបួលគេលេងបាល់។
ទីតូ នៅស្ងៀម រួចដកទូរសព្ទពីហោប៉ៅមកលេង។
រីកា សួរ៖ ម៉េចលួចទូរសព្ទម៉ាក់បងមកលេងអីចឹង?
ទីតូ មិនតប រួចលេងបន្ត។



មិនយូរប៉ុន្មាន មេឃខ្មៅដាសមានផ្គររន្ទះ និងផ្លេកបន្ទោរភ្លឺបភ្លែត ៗ។
វីកា ស្ទុះដណ្ដើមទូរសព្ទមកបិទ៖
បងទីតូ! ការប្រើទូរសព្ទ ឬជ្រកក្រោមដើមឈើ ពេលភ្លៀងមានគ្រោះថ្នាក់ណាស់។
ទីតូ មានះមិនស្ដាប់។ ពួកគេក៏ប្រទាញប្រទង់ដណ្ដើមទូរសព្ទគ្នា។
ចៃដន្យដៃពួកគេក៏ចុចចំប៊ូតុងមួយ។



ស្នូររន្ទះមួយលាន់ឮយ៉ាងខ្លាំង។ មេឃប្រែជាងងឹតស្លុប។ ពន្លឺចម្លែកមួយចុះពីលើមេឃ។ ភ្លាមនោះយានចម្លែកមួយលេចឡើង លាន់សន្ធឹក។
គ្រប់គ្នាផ្អើលព្រោះឃើញសត្វចម្លែកបៃតងមួយដើរចេញមក។
អ្ហ៎! មនុស្សភពក្រៅ និងថាសហោះ!!!



អេលាន និយាយ៖ ខ្ញុំឈ្មោះ អេលាន។ ខ្ញុំចង់ហោះកម្សាន្ត។ តើឯងទៅជាមួយខ្ញុំទេ?

ទីតូ ងក់ក្បាលដើរទៅរក អេលាន។ រីកា ចាប់ដៃគេឃាត់។

ទីតូ មុខមាំ៖ ឯងគួរឲ្យធុញណាស់! ខ្ញុំចង់ដើរលេង! ដឹងទេ ម៉ាក់ខ្ញុំគ្មានពេលជូនខ្ញុំដើរលេងទេ។

បន្ទាប់មក ទីតូ រត់ចូលយានថាសហោះ។

រីកា និងកូនឆ្កែរត់ចូលតាមដោយទាំងអំពិលអំពែកមួយទៅដែរ។



អេលាន វាសដៃលើអេក្រង់មួយ។ ទ្វារយានបិទដោយស្វ័យប្រវត្តិ រួចចេញដំណើរ។
ទីតូ សួរ រីកា៖ ឯងមកធ្វើអី ប្រយ័ត្នប៉ាម៉ាក់ឯងរកមិនឃើញ ?
នាងតបដោយម៉ឺងម៉ាត់៖ ចុះបងឯងវិញ ប៉ាម៉ាក់បងគិតយ៉ាងម៉េច ?




ពួកគេបានឃើញទិដ្ឋភាពព្រៃក ស្ទឹង បឹងបួ ទន្លេ និងសមុទ្រ។
ផុតពីនោះ គេឃើញភូមិ ផ្លូវថ្នល់ និងទីក្រុង។
ទីតូ លាន់មាត់៖ ពិតជាអស្ចារ្យណាស់!
រីកា សួរកូនឆ្កែ៖ ឯងកើតអីហ្នឹង? ប្រហែលជាឯងពុលយាន
ថាសហោះហើយ!



ពួកគេមើលឃើញផែនដីពណ៌ខៀវ។ អេលាន ប្រាប់៖ យាន
ហោះឡើងដល់លំហអវកាស។
រីកា រំភើប៖ អូ! ខ្ញុំមិនដែលឃើញទេ។
ទីតូ បន្ថែម៖ ពិតជាស្អាតណាស់!



ទីតូ ទាញទូរសព្ទមកថតរូប។ ភពនានាបង្ហាញខ្លួនយ៉ាងច្បាស់។ បន្ទាប់មក ព្រះអាទិត្យយ៉ាងធំកំពុងឆេះឧស្ម័ន។



អេលាន ផ្ទាត់ម្រាមដៃ រួចនិយាយដោយមោទនភាព៖ ស្វាត់ៗ
ចាំមើលថាមានអីអស្ចារ្យទៀត!

គេប៉ះគន្លឹះមួយ។ ផ្ទាំងអេក្រង់មួយនៅមុខទីតូបង្ហាញរូបភាព។
ពួកគេឃើញសកម្មភាពមនុស្សភពក្រៅជាច្រើន។



អេលាន វាសអេក្រង់មួយទៀត។ ផ្ទាំងអេក្រង់ធំមួយកំពុង
បញ្ចាំងវីដេអូតុក្កតា។
អេលាន អួត៖ រឿងតុក្កតាអីក៏មានដែរ។ ពួកឯងអាចសាកចុច
មើលតាមចិត្ត។
ទីតូ ចុចមើលរឿងមួយ។ រីកា ប្រកែក៖ ខ្ញុំចង់មើលអានេះវិញ។



អេលាន ឃើញកូនឆ្កែកាន់តែមិនស្រួលខ្លួន។
គេក៏ប្រាប់៖ ឯងសម្រាកទៅក្រែងបានធូរស្រាល។
អេលាន វាសអេក្រង់មួយ។
សាឡុងទំនើប និងកាសចម្រៀងលេចឡើងភ្លាមៗនៅមុខពួកគេ។
រីកា សរសើរ៖ ទីនេះកន្លែងសម្រាកស្រួលខ្លួនមែនទែន។
ទីតូ បន្ថែម៖ មានចម្រៀងស្តាប់ទៀត!



សម្រាកបន្តិច។ អេលាន ចុចគន្លឹះមួយទៀត។ ម៉ាស៊ីនបញ្ចុក
អាហាររាងមឹកលេចឡើង។
ដៃមឹកមួយចាប់បញ្ចុកអាហារ វីកា និង ទីតូ។
កូនភ្លែ និងអំពិលអំពែកនៅតែងលង់លក់នៅឡើយ។



មិនយូរប៉ុន្មានយានរង្គើលាន់គ្រឹប។ គ្រប់គ្នាទប់លំនឹង។
អេលាន ប្រាប់៖ ឥឡូវយើងកំពុងចុះចតលើភពមួយ។
ពួកគេប្រុងស្ទុះចេញទៅ។
ប៉ុន្តែ អេលាន ប្រាប់ឲ្យគ្រប់គ្នាពាក់សម្លៀកបំពាក់ត្រឹមត្រូវ
សម្រាប់ចេញទៅក្រៅភព។



ចេញមកក្រៅយាន វីកាសម្លឹងមើលទីនោះដោយងឿងឆ្ងល់៖ ទីនេះមិនដូចផ្ទះយើងសោះ។

ទីតូ ងក់ក្បាលទឹកមុខក្រៀម៖ មែនហើយ! គ្មានទឹក គ្មានដើមឈើ ហើយក្តៅទៀត។



ស្រាប់តែសន្ទឹកផ្ទុះដ៏កក្រើកមួយបានកើតឡើង។ ធូលីហុយទ្រលោមរកមើលអ្វីមិនយល់។
អេលាន ស្រែកប្រាប់៖ បន្ទុះអាចម៍ផ្កាយធ្លាក់មកហើយ!
ឆាប់ឡើងលើយានភ្លាម! គ្រប់គ្នាភ័យស្លន់ស្លោប្រញាប់រត់តម្រង់យាន។



អេលាន ចាប់ចុចបញ្ជាយាន។ ភ្លាមនោះអាចម៍ផ្កាយដ៏ធំមួយហោះសំដៅមកមុខយាន។
ទីតូ និង រីកា ក៏ស្រែកតំណាលគ្នា៖ គ្រោះថ្នាក់ណាស់!
យានក៏ដំណើរការ ប៉ុន្តែស្នូរប៉ះទង្គិចបានកើតឡើង។



យានហោះចេញគេចដុំអាចម៍ផ្កាយ។ ផុតបន្តិច យានក៏រង្គើយ៉ាងខ្លាំង។

ភ្លើងក្រហមលោតភ្លឹបភ្លែតៗ។ សំឡេងប្រកាសអាសន្នរោទិ៍ មានបញ្ហា! មានបញ្ហា!



ប្រព័ន្ធថាមពលយានឈប់ដំណើរការ។ ពន្លឺអគ្គិសនីដាច់អស់។
យានទាំងមូលងងឹតស្លុបលើអវកាស។
អេលាន បន្លឺឡើង៖ ប្រព័ន្ធខូចហើយ! ប្រព័ន្ធខូចហើយ!
គ្រប់គ្នាបារម្ភ៖ អីចឹងវិវរហើយ! មុខជាស្លាប់មិនខាន!
រីកាបារម្ភ៖ ខ្ញុំចង់ទៅផ្ទះ ខ្ញុំនឹកប៉ាម៉ាក់! យើងត្រូវរកមធ្យោបាយ
ដោះស្រាយឲ្យបាន។



ឃើញពន្លឺអំពិលអំពែក រីកាឆក់ទូរសព្ទពីទីតូមកបំភ្លឺ។
អំពិលអំពែកហោះបញ្ចេញពន្លឺលើម៉ាស៊ីន។
អេលាន ចាប់ត្រួតពិនិត្យជួសជុល។
កូនឆ្កែជួយ រីកា និង ទីតូ រកឧបករណ៍ឲ្យអេលាន។
ពួកគេក៏រកឃើញកន្លែងជួសជុល។



អេលាន ប្រាប់៖ អស់ថាមពលហើយ! ត្រូវការជំនួយ។

ទីតូ ដកយកថ្មទូរសព្ទហុចឲ្យអេលាន៖ ហ៎ ណេះ! សាកដាក់វាចូលទៅ!

រីកា ស្រែកដាស់តឿន៖ លឿនឡើងៗ! អាចម៍ផ្កាយមកទៀតឥឡូវហើយ!

អេលាន ក៏សាកដាក់ថ្មទូរសព្ទចូលក្នុងម៉ាស៊ីនយាន។



ម៉ាស៊ីនថាមពលដំណើរការឡើងវិញ។
អេលាន បញ្ជាយានយ៉ាងរហ័ស។
ទាំងអស់គ្នារំភើបស្រែកថា អស្ចារ្យណាស់ អេលាន! យើងគេចផុតហើយ!
ពួកគេក៏សំដៅមកចុះចតនៅផែនដីវិញ។



មនុស្សភ្ញាក់ផ្អើលឈូឆរមើលគ្រប់គ្នា។ ប៉ាម៉ាក់ទីតូ និង រីកាស្ទុះ
មកឱបពួកគេទាំងទឹកភ្នែក។
ពួកគេរីករាយណាស់ពេលបានត្រឡប់មកវិញ។
អេលាន ក៏លាពួកគេត្រឡប់ទៅវិញ។
ទីតូ ទាញទូរសព្ទពីក្នុងហោប៉ៅហុចឲ្យម៉ាក់វិញ។ ប៉ុន្តែទូរសព្ទ
គ្មានថ្មទេ។
ទីតូស្រែក៖ ឈប់ៗ! អេលាន! កុំភ្លេចសងថ្មទូរសព្ទខ្ញុំវិញ ។



ពេលនោះទីតូក៏ភ្ញាក់ដឹងខ្លួនធ្លាក់ពីលើគ្រែទាំងដៃកាន់ទូរសព្ទ។
រីកា និងកូនឆ្កែក៏រត់ចូលមកមើល។
ទីតូ សើចស្នាញប្រាប់រីកា៖ ខ្ញុំយល់សប្តិឃើញអេលាន!
រីកាលាន់មាត់៖ ខ្ញុំក៏ដូចគ្នាដែរ ។
ពួកគេនឹកភ្នកមើលមកទូរសព្ទ ក៏ភ្ញាក់ផ្អើលយ៉ាងខ្លាំង។
នោះគឺរូបថតដំណើរកម្សាន្តដ៏អស្ចារ្យរបស់ពួកគេជាមួយ អេលាន។

ចប់

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Amazing Adventure*, Author: Kim Ann Arun. Illustrator: Seat Sopheap. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2017. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang